ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.....................

**សារលិខិត**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងជូនជនរួមជាតិ ក្នុងឱកាសទិវាជាតិយល់ដឹងពីមីន លើកទី១៧**

**ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦**

ជនរួមជាតិជាទីស្រលាញ់រាប់អាន!

ថ្ងៃទី២៤ ខែកុម្ភៈ នេះ ជាទិវាជាតិយល់ដឹងពីមីន ដែលព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ដើម្បីរំលឹកប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេស បងប្អូនជនរួមជាតិដែលរស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ឲ្យមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយសារគ្រាប់ទាំងនោះ ។

គ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលជាកេរដំណែលបន្សល់ទុកពីសង្គ្រាមឥណ្ឌូចិន និងជម្លោះផ្ទៃក្នុងកម្ពុជាក្នុងរយៈពេលបីទសវត្សរ៍ មិនត្រឹមតែបង្កសោកនាដកម្មដ៏ធ្ងន់ធ្ងរចំពោះអាយុជីវិតប្រជាពលរដ្ឋរបស់យើងតែប៉ុណ្ណោះទេ តែថែមទាំងជាឧបសគ្គសម្រាប់ការស្តារ និងអភិវឌ្ឍន៍ជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិទៀតផង។ ដើម្បីដោះស្រាយបញ្ហារាំងស្ទះនេះ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកវិស័យសកម្មភាពមីនជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៨ ជាពិសេសសម្រាប់កម្ពុជា និងបានបញ្ចូលវិស័យនេះជាធាតុមួយដ៏សំខាន់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន។ គិតមកដល់ឆ្នាំ២០១៦ សកម្មភាពបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមជាលក្ខណៈមនុស្សធម៌នៅកម្ពុជា មានរយៈពេល ២៤ឆ្នាំមកហើយ។ ក្នុងរយៈពេលនេះ ប្រតិបត្តិករសកម្មភាពមីនទាំងអស់ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល រួមនឹងដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ ក្រោមការសម្របសម្រួល របស់អាជ្ញាធរមីន បានប្រឹងប្រែងរួមគ្នាសម្រេចរំដោះដីមានមីនបានជាង ១៤០០គីឡូម៉ែត្រក្រឡា ជូនប្រជាពលរដ្ឋសម្រាប់កសាងភូមិដ្ឋាន ធ្វើស្រែចំការ កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា និងបានរកឃើញ និងកំទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន ១.០២៣.២៩៨គ្រាប់ គ្រាប់មីនប្រឆាំងរថក្រោះ ២៣.៨៥៤គ្រាប់ សំណល់ជាតិផ្ទុះពីសង្គ្រាម ២.៦១៤.១៩១គ្រាប់ ព្រមទាំងបានធ្វើឲ្យចំនួនអ្នករងគ្រោះធ្លាក់ចុះពីជាង ៤.០០០នាក់ ក្នុងឆ្នាំ១៩៩៦ មកត្រឹម១១១នាក់ ក្នុងឆ្នាំ២០១៥ កន្លងទៅ ។

ទោះជាយ៉ាងនេះក្តី ផ្អែកតាមរបាយការណ៍របស់អាជ្ញាធរមីន បានបង្ហាញថា៖ កម្ពុជានៅមានផ្ទៃដីសង្ស័យថាមានមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះប្រមាណជាង ១៦០០ គីឡូម៉ែត្រក្រឡាទៀត ដែលត្រូវធ្វើការបោសសំអាត។ គួរកត់សំគាល់ថា ក្នុងរយៈពេលបីឆ្នាំចុងក្រោយ គិតចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៥ បញ្ហាគ្រោះថ្នាក់ដោយសារមីនគោននៅតែបន្តកើតមានឡើងជាញឹកញាប់ ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងចក្រធុនធ្ងន់នៅក្នុងតំបន់ដែលមានផលប៉ះពាល់ដោយសារមីនគោន។ ទន្ទឹមនឹងនេះគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម ក៏នៅតែបង្កឲ្យប្រជាពលរដ្ឋយើង ធ្លាក់ខ្លួនពិការ ស្លាប់បាត់បង់ជីវិត មនុស្ស សត្វពាហនៈ និងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន។

ជនរួមជាតិជាទីស្នេហា !

កិច្ចប្រតិបត្តិការបោសសម្អាតមីនតែមួយផ្នែក មិនអាចផ្តល់សុវត្ថិភាពទាំងស្រុងជូនប្រជាពលរដ្ឋបានឡើយ។ ការងារគួបផ្សំដ៏សំខាន់មួយទៀតនៃវិស័យសកម្មភាពមីន គឺការអប់រំឲ្យប្រជាពលរដ្ឋបានយល់ដឹងអំពីគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ។

តាមរយៈការសម្របសម្រួលរបស់អាជ្ញាធរមីន រាជរដ្ឋាភិបាលបានជំរុញ និងគាំទ្រនូវកម្មវិធី និងវិធានការជាច្រើន ដើម្បីទប់ស្កាត់និងកាត់បន្ថយចំនួនគ្រោះថ្នាក់ និងសង្គ្រោះជនរងគ្រោះនានា ដោយបានជំរុញការងារអប់រំដោយផ្ទាល់នៅតាមខ្នងផ្ទះ តាមសហគមន៍ តាមរយៈចលនាកីឡា ការផ្សព្វផ្សាយទូលាយតាមវិទ្យុ និងទូរទស្សន៍ ផ្ទាំងប៉ាណូ ខិត្តប័ណ្ណ និងរហូតដល់ការបញ្ចូលសារអប់រំពីមីនទៅក្នុងកម្មវិធីសិក្សា ព្រមទាំងការអនុវត្តន៍ច្បាប់គ្រប់គ្រងអាវុធជាតិផ្ទុះ និងវិធានការរដ្ឋបាលនានាបែមទៀត។

ក្នុងឱកាសនៃទិវាជាតិយល់ដឹងពីមីន ២៤ កុម្ភៈ លើកទី១៧ នេះ ខ្ញុំសូមធ្វើការអំពាវនាវជូនដល់អាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ ប្រតិបត្តិករសកម្មភាពកំចាត់មីន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រជាពលរដ្ឋកម្ពុជា ដូចតទៅ៖

១/ អាជ្ញាធរដែនដី ត្រូវរួមសហការ និងលើកទឹកចិត្តប្រតិបត្តិករសកម្មភាពមីន និងអង្គការពាក់ព័ន្ធគាំទ្រនិងជំរុញការអនុវត្តន៍កម្មវិធីអប់រំដល់ប្រជាពលរដ្ឋទូទៅ ពិសេសប្រជាពលរដ្ឋនៅតាមសហគមន៍ដែលងាយរងគ្រោះថ្នាក់ ឲ្យបានជ្រួតជ្រាបពីហេតុផលរងគ្រោះថ្នាក់ និងផលវិបាកនៃគ្រោះថ្នាក់ ព្រមទាំងមានវិធានការឲ្យបានតឹងរឹង ចំពោះទង្វើនៃការលេង ឬកែច្នៃគ្រាប់ ដែលតែងតែបង្កអោយមានគ្រោះថ្នាក់ ។

២/ ប្រតិបត្តិករ និងដៃគូអភិវឌ្ឍន៍ ចូលរួមឲ្យបានខ្លាំងក្លាថែមទៀតក្នុងការជួយកាត់បន្ថយចំនួនគ្រោះថ្នាក់ ដោយត្រូវខិតខំបន្តបង្កើននូវសមត្ថភាពបោសសម្អាតមីន ឆ្លើយតបទៅនឹងសំណូមពរជាបន្ទាន់របស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ចំពោះមុខ ដោយគួបផ្សំនឹងវិធានការបច្ចេកទេសនានា ដូចជាការដាក់សញ្ញាសម្គាល់ជាដើម ឲ្យប្រជាពលរដ្ឋបានដឹងអំពីតំបន់គ្រោះថ្នាក់។

៣/ ចំពោះបងប្អូនប្រជាពលរដ្ឋ ពិសេសកុមារា កុមារី៖

- សូមចូលរួម និងចងចាំក្នុងស្មារតីថា ត្រូវគោរពប្រតិបត្តិតាមការអប់រំ ការប្រាប់ ការបង្ហាញរបស់អាជ្ញាធរមូលដ្ឋាន អាណាព្យាបាល ក៏ដូចជាអង្គការទាំងឡាយ ដែលបានអប់រំបងប្អូន កូនៗ អំពីគ្រោះថ្នាក់ទាំងនេះ ។

- ត្រូវរាយការណ៍ជាបន្ទាន់ឲ្យអាណាព្យាបាល សមត្ថកិច្ចនគរបាល ឬអង្គភាពបោសសម្អាតមីន ដែលនៅជិតបំផុត ពីកន្លែងគ្រាប់មីន ឬគ្រាប់យុទ្ធភ័ណ្ឌ ដែលបងប្អូន ក្មួយៗ បានជួប ឬបានប្រទះឃើញ ដោយកុំប៉ះពាល់វាជាដាច់ខាត ។
- មិនត្រូវថ្លៃ និងប្រកបរបរជាមួយនឹងគ្រឿងផ្ទុះ ហើយត្រូវសាកសួរអាជ្ញាធរ ឬអ្នកដែលដឹងច្បាស់អំពីព័ត៌មានតំបន់ដែលបងប្អូន ក្មួយៗមានបំណងប្រើប្រាស់ដី ធ្វើដំណើរឆ្លងកាត់ ឬរុករកអនុផលព្រៃឈើ ។
- មិនត្រូវប្រើប្រាស់គ្រឿងចក្រធុនធ្ងន់ដើម្បីចូលធ្វើការរុករានដីព្រៃ ឬដីចំការ ដែលនៅមិនទាន់បានធ្វើការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលអាចបង្កឲ្យមានគ្រោះថ្នាក់ ជាពិសេសគ្រោះថ្នាក់ដោយសារមីនតោន។

ខ្ញុំសូមឆ្លៀតឱកាសដ៏មហោឡារិកនេះ សម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុត ជូនចំពោះដៃគូអភិវឌ្ឍន៍ បណ្តាអង្គការជាតិ-អន្តរជាតិ និងប្រតិបត្តិករសកម្មភាពមីនទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងបេសកកម្មបោសសម្អាតមីន និងរាល់ប្រតិបត្តិការសកម្មភាពមីននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងលើកកម្ពស់សុវត្ថិភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាយើងខ្ញុំ ឲ្យបានប្រសើរជាលំដាប់ រួមចំណែកស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឲ្យបានកាន់តែរុងរឿងថ្កុំថ្កើងហើសថែមទៀត។ ខ្ញុំសូមប្រសិទ្ធពរជូនបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ!

រាជធានីភ្នំពេញ, ថ្ងៃទី      ខែ កុម្ភៈ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**